GMAC
Garment Manufacturers Association in Cambodia

# សេចក្តីថ្លែងការណ៍

*ភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧:*

សមាគមរោងចក្រកាត់ដេរនៅកម្ពុជា(GMAC) សំដែងការកោតសរសើរនិងអំណរគុណចំពោះអ្នកបញ្ជាទិញ Walmart ដែលជាអ្នកបញ្ជាទិញអន្តរជាតិរបស់អាមេរិក ចំពោះការប្តេជ្ញាចិត្តនិងបន្តគាំទ្រឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់និងស្បែកជើងព្រមទាំងទំនិញសម្រាប់ធ្វើដំណើរ(travel goods)របស់កម្ពុជាជាប់ជានិច្ច។

បើតាមលិខិតរបស់អ្នកបញ្ជាទិញ Walmart ដែលផ្ញើទៅឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរបស់កម្ពុជា ចុះថ្ងៃទី៦ ខែធ្នូ បានឲ្យដឹងថា បន្ទាប់ពីដំណើរទស្សនកិច្ចនាពេលថ្មីៗរបស់គណៈប្រតិភូ Walmart កាលពីថ្ងៃទី៧ ខែវិច្ឆិកា ដើម្បីជួបផ្ទាល់ជាមួយមន្ត្រីរដ្ឋាភិបាលកម្ពុជាមួយចំនួន និងទស្សនកិច្ចរោងចក្រស្បែកជើងមួយចំនួនដទៃៗទៀត ព្រមទាំងសហការីរបស់ខ្លួនដែលធ្វើការនៅក្នុងរាជធានីភ្នំពេញ អ្នកបញ្ជាទិញ Walmart បានថ្លែងថា កម្ពុជាជាទីផ្សារសំខាន់សម្រាប់ Walmart។

លិខិតនេះបានសរសេរថា៖ «យើងជាអ្នកនាំចេញស្បែកជើងនាំមុខគេរបស់កម្ពុជា និងជាអ្នកនាំចេញសម្លៀកបំពាក់នាំមុខគេទីពីរ។ ឆ្នាំក្រោយ យើងសង្ឃឹមថា នឹងនាំចេញផលិតផលសម្រាប់ធ្វើដំណើរ(travel product)»។ «យើងរីករាយចែករំលែកបទពិសោធន៍របស់យើងដែលធ្វើការងារជាមួយទីផ្សារទិញដទៃៗទៀត និងជួយរោងចក្រកម្ពុជាបង្កើនសមត្ថភាពប្រកួតប្រជែង ផលិតភាព និងប្រសិទ្ធភាព»។

លិខិតនេះបន្តថា៖ «ភាពរីកចម្រើនរបស់យើងក្នុងប្រទេសកម្ពុជាពឹងផ្អែកលើបរិយាកាសអាជីវកម្មរឹងមាំ។ ស្ថិរភាព ភាពអាចព្យាករណ៍បាន និងនីតិរដ្ឋ គឺជាភាពដ៏សំខាន់សម្រាប់អាជីវកម្មរបស់យើងជុំវិញពិភពលោក ហើយធ្វើឲ្យយើងអាចធ្វើការប្តេជ្ញាចិត្តនិងវិនិយោគរយៈពេលវែងនៅក្នុងទីផ្សារមួយ»។

GMAC បានថ្លែងថា៖ «ដូច្នេះការគាំទ្ររបស់ Walmart មានន័យថាជាការរួមចំណែកដល់ការបន្តអាជីវកម្មនិងវិនិយោគរបស់កម្ពុជាដើម្បីគាំទ្រសេដ្ឋកិច្ចរបស់យើង។ ជាងនេះទៀត យើងក៏នឹងទំនងជាទទួលអត្ថប្រយោជន៍ច្រើនផងដែរពីជំនាញរបស់ Walmart ដែលរួមមានការច្នៃប្រឌិតនិងបច្ចេកវិទ្យាព្រមទាំងរបៀបដែលវិស័យសម្លៀកបំពាក់និងស្បែកជើងក្នុងសកលលោកប្រតិបត្តិ»។ បើតាមលិខិតនេះ Walmart គោរពតាមស្តង់ដារខ្ពស់និងយកចិត្តទុកដាក់ចំពោះលក្ខខណ្ឌការងារនិងសង្គមនៅក្នុងប្រទេសដែលខ្លួនបញ្ជាទិញ។

GMAC បានថ្លែងបន្តថា៖ «អនុលោមភាពការងារគឺជាចំណុចមួយក្នុងចំណោមចំណុចសម្រាប់ពិចារណានៅក្នុងការគ្រប់គ្រងលទ្ធផលយុទ្ធសាស្ត្ររបស់អ្នកបញ្ជាទិញ។ ការចូលរួមជាបន្តរបស់ Walmart ជាមួយយើងមានន័យថា យើងកំពុងធ្វើបានលទ្ធផល ឬនិយាយឲ្យច្បាស់គឺធ្វើបានទៅតាមស្តង់ដារដែលទទួលយកបានជាអន្តរជាតិ»។

GMAC បានបន្តថា៖ «ខណៈពិភពលោកកំពុងឆ្ពោះទៅរកគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព អនុលោមភាពគឺជាកត្តាសំខាន់និងមានឥទ្ធិពលនៅក្នុងកាតដាក់ពិន្ទុ»។ កាតដាក់ពិន្ទុរួមមាន ១) តម្លៃ ២) គុណភាព ៣) ការដឹកញ្ជូន និង៤) អនុលោមភាពការងារនិងសង្គម។



តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ភូមិត្រពាំងគល់ សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Phnom Penh Special Economic Zone, Trapeang Kul Village, Sangkat Kantouk, Khan Por Sen Chey, Phnom Penh Cambodia.
Tel: (855) 23-88 34 35 E-mail: info@gmac-cambodia.org Website: www.gmac-cambodia.org